BBI0073

# សម្ភាសជាមួយឈ្មោះ ប្រាក់ រុន ភេទ ស្រី អាយុ ៥៦ឆ្នាំ

មុខងារខ្មែរក្រហមៈ ធ្វើស្រែ

មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ

មានស្រុកកំណើតនៅៈ ភូមិព្រៃចេក ឃុំ ស្រុកជុំគីរី ខេត្តកំពត

សព្វថ្ងៃរស់នៅភូមិស្វាយជ្រុំ ឃុំអូដារ ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ស សេងគា

០០:២៨:២៨

២២ ទំព័រ

សេងគា ៖ បាទ!អ៊ំស្រីខ្ញុំឈ្មោះសេងគា ខ្ញុំម៉ោនេះខ្ញុំសុំសួរនាំអ៊ំអំពីជីវប្រវត្តិអ៊ំតាំងពីក្មេងរហូតដល់ចាស់ប្រវត្តិផ្ទាល់ខ្លួនអ៊ំ អ៊ំជួបបញ្ហាអីខ្លះ ហើយពីតូចម៉ោអ៊ំធ្វើអីខ្លះរហូតដល់ឥឡូវអ៊ំណាស់ ហើយអ៊ំរស់នៅនេះពីឆ្នាំណាអញ្ចឹង បាទ!អញ្ចឹងហើយចំណុចណាដែលខ្ញុំសួរអ៊ំទៅអ៊ំឆ្លើយបានក៏ឆ្លើយបានក៏អ៊ំឆ្លើយទៅ ហើយចំណុចណាដែលអ៊ំឆ្លើយមិនបានក៏អត់អីដែរអ៊ំ អ៊ំថាអត់ដឹងក៏អត់ដឹងទៅ ព្រោះអីរឿងរ៉ាវតាំងពីតូចម៉ោមានអ្នកភ្លេចហើយអ៊ំភ្លេចចាំអីជារឿងធម្មតាទេចាស់ហើយ ព្រោះខ្ញុំសុម្បីខ្ញុំនៅក្មេងក៏ខ្ញុំនៅភ្លេចដែរ បាទ! ហើយខ្ញុំឈ្មោះសេងគា ម៉ោពីមជ្ឈមណ្ឌលកម្ពុជា ចង់បានបទសម្ភាសន៍ពីអ៊ំហ្នឹងគឺដើម្បីយកចងក្រងជាឯកសារដើម្បីឲ្យក្មេងបានដឹងមនុស្សម្នាក់ៗពីមុនម៉ោវ៉ាចេះ បើក្មេងសម័យឥឡូវប្រាប់អីពីរឿងមុនមិនសូវជឿទេអ៊ំ ដូច្នេះហើយគឺដើម្បីចងក្រងជាឯកសារជាភស្តុតាងមួយគឺមានតាំងពីរូបអ៊ំ ឃើញរូបអ៊ំផងហើយអ៊ំបានរៀបរាប់រឿងរ៉ាវពីមុនរបស់អ៊ំផងអីអញ្ចឹង ដើម្បីយកទុកចងក្រងជាឯកសារអី ចុះអ៊ំយល់យ៉ាំងម៉េច ដែរ?

រុន ៖ ខ្ញុំអត់ចេះនិយាយអីទេ អក្សរក៏អត់ចេះ ។

សេងគា ៖ អ៊ំនៅស្រុកណាដែរអ៊ំ?

រុន ៖ ខ្ញុំនៅកំពត ស្រុកជុំគីរី ។

សេងគា ៖ អូរស្រុកជុំគីរីកំពត?

រុន ៖ ចា៎!ប៉ុន្ទខ្ញុំម៉ោតាំងពីសង្គ្រាមនោះម៉ោរហូត ។

សេងគា : អញ្ចឹង!កាលហ្នឹងមិនទាន់មានគ្រួសារទេអី?

វុន : រត់ម៉ោមានហើយ ការហើយម៉ោរហូតអត់ដែលស្គាល់ផ្ទះទេ ។

សេងគា : អូររត់តាមស្វាមីម៉ោរហូតម៉ោ?

វុន : ចា៎!ខ្ញុំអត់ចេះអីគេទេ អក្សរក៏មិនចេះ និយាយក៏មិនចេះ ។

សេងគា : អត់អីទេខ្ញុំសួរអ៊ី អ៊ីឆ្លើយបានប៉ុណ្ណាឆ្លើយប៉ុនហ្នឹងអ៊ី បាទ!ខ្ញុំគ្រាន់តែសុំអាប់ជាសំលេង ដើម្បីយកទៅសរសេរ ព្រោះខ្ញុំចាំអត់អស់អ៊ី យកសរសេរដើម្បីជាសាច់រឿងរបស់អ៊ី រឿងប៉ាវរបស់ខ្ញុំក៏គាត់ធ្លាប់តស៊ូអញ្ចឹងដែរ អញ្ចឹងខ្ញុំបានសរសេរចុះរៀបរាប់ហើយ ដើម្បីទុកឲ្យកូនៗបានដឹង ព្រោះអីប្អូនខ្ញុំអី គាត់ឥឡូវរៀននៅមហាវិទ្យាល័យហើយ ប៉ុនគាត់អត់ដឹងទេនិយាយក៏អត់ចង់ជឿដែរ គ្នាអ្នកណាបន្ទត់បាយបន្ទត់អីអញ្ចឹងពីមុន ម៉ោអញ្ចឹង បាទ!អញ្ចឹងខ្ញុំសុំបទសម្ភាសន៍របស់អ៊ីយកទៅប្រើប្រាស់អញ្ចឹងអ៊ីថាម៉េច ដែរ?

វុន : ខ្ញុំអត់ចេះនិយាយគេទេ ។

សេងគា : បាទ!អញ្ចឹងខ្ញុំសម្ភាសន៍អ៊ីទៅ អ៊ីឆ្លើយបានប៉ុន្មានយកប៉ុនហ្នឹងអ៊ី ថ្ងៃនេះថ្ងៃទី១៩ខែ៣ ឆ្នាំ២០១១ បាទ!ដូចថាខ្ញុំរៀបរាប់ថ្ងៃនេះដើម្បីទុកចងក្រងជាឯកសារទេសម្រាប់ មនុស្សម្នាក់ៗ ខ្ញុំម៉ោសម្ភាសន៍តាមភូមិឃុំច្រើននៅក្នុងស្រុកកំរៀងនេះ ហើយម៉ោហ្នឹង គឺជួបពីឯកឧត្តម សុខ គង់ ម៉ោចុះមកដល់ស្រុក ស្រុកចុះមកដល់ឃុំ ឃុំចុះមកដល់ ភូមិទៀត មកទំនាក់ទំនងអ៊ីពូមីងហ្នឹងតាមរយៈលោកមេភូមិអញ្ចឹង បាទ!អញ្ចឹងខ្ញុំចង់ ស្គាល់ឈ្មោះអ៊ី អ៊ីឈ្មោះអីដែរ?

វុន : ខ្ញុំឈ្មោះ វុន ។

សេងគា : អីវុនដែរ?

វុន : ប្រាក់ វុន ។

សេងគា : អ៊ីអាយុប៉ុន្មានហើយអ៊ី?

វុន : ៥៦ឆ្នាំហើយ ។

សេងគា : អ៊ីមានស្រុកកំណើតនៅណាដែរអ៊ី?

វុន : នៅឯជុំគីរីហ្នឹងស្រុកកំណើតខ្ញុំ ។

សេងគា : ភូមិអីដែលអ៊ី?

វុន : ភូមិព្រៃចេក ។

សេងគា : ព្រៃចេក?

វុន ៖ ចា៎!

សេងគា ៖ ឃុំ?

វុន ៖ ភ្លេចបាត់ហើយ អត់ចាំទេ ។

សេងគា ៖ នៅស្រុកជុំគីរី ខេត្តកំពតអ៊ំ?

វុន ៖ ចា៎!

សេងគា ៖ អញ្ចឹងបច្ចុប្បន្នរស់នៅភូមិនេះភូមិស្វាយជ្រុំអ៊ំ?

វុន ៖ ចា៎!

សេងគា ៖ ឃុំអូរដារ ស្រុកកំរៀងខេត្តបាត់ដំបង ។ ឪពុកអ៊ំឈ្មោះអីដែរអ៊ំ?

វុន ៖ ឈ្មោះ ទន់ ម៉ែខ្ញុំឈ្មោះ ខាត់ ។

សេងគា ៖ មានចាំត្រកូលគាត់ទេ?

វុន ៖ ប្រាក់ វុនហ្នឹងត្រកូលគាត់ហើយ ។

សេងគា ៖ ប្រាក់អីគេឪពុក?

វុន ៖ ប្រាក់ ទន់ ។

សេងគា ៖ គាត់នៅរស់ឬក៏ស្លាប់ហើយ?

វុន ៖ អូរអស់ហើយ ។

សេងគា ៖ ស្លាប់ពីពេលណាម៉ោអ៊ំ?

វុន ៖ អត់ដឹងផងខ្ញុំទៅផ្ទះអស់រលីងហើយ អត់ដែលឃើញមុខគាត់ផងតាំងពីខ្ញុំម៉ោ ។

សេងគា ៖ ចុះម្ដាយអ៊ំ?

វុន ៖ អស់រលីង ។

សេងគា ៖ ម្ដាយឈ្មោះអីអ៊ំ?

វុន ៖ ខាត់ ទន់ ។

សេងគា ៖ អ៊ូ!ដាក់ខាត់ ទន់ ស្លាប់ជាមួយគ្នាកាលហ្នឹងអ៊ំ?

វុន ៖ មិនដឹងស្លាប់ពីថ្ងៃណាខែណាអត់ដែលដឹង ។

សេងគា ៖ ប៉ុន្តែនៅក្នុងចំណោមសង្គ្រាមហ្នឹង ៧៩ហ្នឹង?

វុន ៖ ចា៎!ព្រោះខ្ញុំទៅស្រុកអត់ដែលឃើញម៉ែឃើញឪផង ។

សេងគា ៖ អត់មានដែលសួរគេទេបងប្អូនស្លាប់អី?

វុន ៖ សួរប៉ុនខ្ញុំអត់ចេះចាំ ។

សេងគា ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់ដែលអ៊ំ បងប្អូនទាំងអស់បងប្អូនបង្កើត?

វុន ៖ ស្លាប់អស់ហើយ ។

សេងគា ៖ បាទទាំងស្លាប់ទាំងរស់?

វុន ៖ ៧នាក់ ។

សេងគា ៖ ៧នាក់?

វុន ៖ ចាំ!ឥឡូវនៅប៉ុន្មានមិនដឹង៤ឬ៥ទេ ។

សេងគា ៖ ស្លាប់អស់ប៉ុន្មានអ៊ំ?

វុន ៖ បងបង្អស់មួយ ពៅមួយអស់ពីរ ស្លាប់ក្នុងសមរភូមិទាំងអស់ ។

សេងគា ៖ បងបង្កើតបងទីមួយ នឹងប្អូនពៅ?

វុន ៖ បងទីមួយនៅ បន្ទាប់ស្លាប់នឹងពៅ ។

សេងគា ៖ ស្លាប់នៅឆ្នាំណា?

វុន ៖ អត់ចាំទេ ។

សេងគា ៖ បាទ!អ៊ំនៅឈ្មោះបងប្អូនអ៊ំទាំងអស់ចាំទេឥឡូវ?

វុន ៖ ចាំ ។

សេងគា ៖ ទី១ឈ្មោះអីគេអ៊ំ?

វុន ៖ ទី១ឈ្មោះ គេង ។

សេងគា ៖ ឈ្មោះប្រាក់ គេង?

វុន ៖ ចាំ!បន្ទាប់មៅ ប្រាក់ ទន់ ។

សេងគា ៖ ប្រាក់ គេង ប្រុសឬស្រីអ៊ំ?

វុន ៖ ប្រុស ។

សេងគា ៖ ទី២?

វុន ៖ ឈ្មោះឃឿន ស្រី ។

សេងគា ៖ ទី៣អ៊ំ?

វុន ៖ ទី៣ឈ្មោះ ទូច ។

សេងគា ៖ ទូច ស្រីដែរ?

វុន ៖ ប្រុស ។

សេងគា ៖ ទី៤?

រុន ៖ ឈ្មោះ រិន ។

សេងគា ៖ ស្រីឬប្រុសអ៊ំ?

រុន ៖ ស្រី ។

សេងគា ៖ ទី៥អ៊ំ?

រុន ៖ ចាំ!

សេងគា ៖ ទី៦?

រុន ៖ ភ្លេចបាត់ហើយភ្លេចមួយបាត់ហើយ នៅតែអាពៅហ្នឹង ។

សេងគា ៖ អាពៅឈ្មោះអី?

រុន ៖ អ្ហូ!ញឹម ដាក់ហើយឬនៅមិញ?

សេងគា ៖ នៅ ។

រុន ៖ ញឹមបន្ទាប់ខ្ញុំ ។

សេងគា ៖ ប្រុសឬស្រីហ្នឹង?

រុន ៖ ប្រុស ។

សេងគា ៖ ប្អូនពៅស្រីឬប្រុសស្លាប់ហ្នឹង?

រុន ៖ ប្រុស ។

សេងគា ៖ ឈ្មោះអីអ៊ំ?

រុន ៖ ឈ្មោះញ៉ ។

សេងគា ៖ បាទ!ប្ដីរបស់អ៊ំឈ្មោះអីដែរអ៊ំ?

រុន ៖ ទេព ឈើន ។

សេងគា ៖ ទេព ឈើន?

រុន ៖ ចាំ!

សេងគា ៖ គាត់អាយុប៉ុន្មានហើយ?

រុន ៖ ភ្លេចបាត់ហើយអត់ដឹងទេ ។

សេងគា ៖ ហើយរាល់ថ្ងៃគាត់ធ្វើអី?

រុន ៖ អត់ធ្វើអីទេ រាល់ថ្ងៃរ៉ុគ្រែកហើយ ។

សេងគា ៖ ពីមុនគាត់ធ្វើអីអ៊ំ?

រុន ៖ ធ្វើទាហាន ។

សេងគា : នៅកងពលណាអ៊ំ?

វុន : អត់ដឹងទេ ។

សេងគា : ជាមួយកូនចៅពូ សុខ គង់?

វុន : អត់ដឹងទេ នៅជាមួយគាត់មិនដឹង ។

សេងគា : គាត់អ្នកស្រុកណាដែលអ៊ំ?

វុន : នៅហ្នឹងជាមួយគ្នាហ្នឹង ។

សេងគា : ប្តីអ៊ំគាត់អ្នកស្រុកណា?

វុន : នៅស្រុកជាមួយខ្ញុំហ្នឹងឯង ។

សេងគា : នៅស្រុកកំពត?

វុន : ចា៎!

សេងគា : ការនៅកំពតហើយរត់ម៉ោជាមួយគ្នា?

វុន : ចា៎!ការហើយរត់ម៉ោទាំងអស់គ្នា ។

សេងគា : គាត់ទឹមរុំគ្រែកទេធ្វើទាហាន?

វុន : រុំគ្រែកយូរហើយ តាំងពីលើកទី១នោះចាស់ហើយគាត់ឈប់ទៅធ្វើ ។

សេងគា : កាលហ្នឹងគាត់កាន់ខាងអីគេទាហានហ្នឹង?

វុន : គាត់គ្មានកាន់អីគាត់ផង ។

សេងគា : អញ្ចឹងដល់ពេលរុំគ្រែកហ្នឹងក៏ឈប់ទៅ?

វុន : ចា៎!ឈឺច្រើនពេក ហើយក៏ចាស់ហើយក៏រំសាយទៅ ។

សេងគា : ហើយអ៊ំមានកូនប៉ុន្មាននាក់ដែលអ៊ំ?

វុន : កូនខ្ញុំ៤នាក់ ប៉ុនអស់ហើយនៅតែ៣នាក់ទេ ។

សេងគា : ៤នាក់ ស្លាប់អស់១នាក់អញ្ចឹង?

វុន : ស្លាប់១ហើយ ។

សេងគា : ស្លាប់កូនច្បង?

វុន : បន្ទាប់ពៅ ។

សេងគា : កូនទី៣ ស្លាប់ដោយសារអីអ៊ំកាលហ្នឹង?

វុន ៖ វាស្លាប់នៅនេះធំហើយរៀនចប់ហើយ រៀនចំថ្នាក់ទី១២ហើយហ្នឹង ចង់ក រកមូល ហេតុអត់ឃើញផង វវល់តែទៅចំការទៅអីអញ្ចឹងទៅ គ្រាន់តែខ្ញុំម៉ោពីចំការយប់ហ្នឹង វាស្លាប់យប់ហ្នឹង ។

សេងគា ៖ កូនទី១អីឈ្មោះអីអុំ?

វុន ៖ ឈឿន ។

សេងគា ៖ ប្រាក់ ឈឿនដែរអុំ?

វុន ៖ ចាំ!

សេងគា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មានកូនអុំ?

វុន ៖ ប្រុស៣ ស្រី១ ស្រីពៅ១នាក់ ។

សេងគា ៖ បាទ!ទី២ឈ្មោះអីអុំ?

វុន ៖ ម៉ាង កាលវាដាក់នៅក្នុងសៀវភៅគ្រួសារវាដាក់គា តែឥឡូវវាប្រើអាហ្នឹងឯង ។

សេងគា ៖ ប្រាក់ ម៉ាង?

វុន ៖ ទី៣ឈ្មោះ ដា ។

សេងគា ៖ ប្រាក់ ដា?

វុន ៖ ទី៤ មុំ ។

សេងគា ៖ ប្រាក់ មុំ?

វុន ៖ ចាំ!

សេងគា ៖ ឈឿន ហ្នឹងអាយុប៉ុន្មានហើយអុំ?

វុន ៖ ២០ជាងហើយមិនដឹង ។

សេងគា ៖ កើតទាន់ខ្មែរក្រហមទេ?

វុន ៖ ទាន់ ។

សេងគា ៖ អ៊ូ!ទាន់ដែរ ម្ភៃប៉ុន្មានអុំ ខ្មែរក្រហមមិន៣០ជាងហើយ?

វុន ៖ ២៥-២៦ហើយមិនដឹង ។

សេងគា ៖ អ៊ូ!៧៦-៧៧-៧៨អត់ទាន់ទេ កើត៨០ជាងហើយ?

វុន ៖ ប៉ុនកាលកើតហ្នឹង គេនៅរត់នៅឡើយអត់ទាន់ឈប់រត់ទេ ។

សេងគា ៖ អញ្ចឹងប្រាក់ ដាហ្នឹងស្លាប់អុំ?

វុន ៖ ស្លាប់ហើយ ។

សេងគា ៈ បាទ!អញ្ចឹងខ្ញុំចង់ដឹងប្រវត្តិអ៊ំអីក្មេងបន្តិច ពីក្មេងស្រុកកំណើតអ៊ំនៅជុំគីរី កាលហ្នឹងឪពុកម្តាយអ៊ំធ្វើអីទៅកាលហ្នឹង?

វុន ៈ អត់ដឹងធ្វើអីទេ ដឹងតែគាត់ធ្វើស្រែ ។

សេងគា ៈ អ៊ំអត់បានចូលរៀនទេ?

វុន ៈ ខ្ញុំអត់ ។

សេងគា ៈ ម៉េចបានអត់ចូលរៀនអញ្ចឹងអ៊ំ?

វុន ៈ មិនដឹងដែរ ដោយសារខ្វះខាតពេកគ្មានអ្នកណាមើលគោមើលក្របី បងក៏រៀន ប្អូនក៏រៀន ។

សេងគា ៈ អញ្ចឹងអ៊ំស្ម័គ្រចិត្តមើលគោ ក្របី?

វុន ៈ មើលគោ ក្របីហ្នឹងទៅនៅជាប់នឹងដៃ ។

សេងគា ៈ អញ្ចឹងអត់បានរៀនមួយឆ្នាំអីសោះអ៊ំ?

វុន ៈ អត់រៀនអីបន្តិចទេ បងប្អូន២នាក់ស្រីៗអត់ចេះទាំងអស់ ។

សេងគា ៈ អ៊ំមានគ្រួសារនៅអាយុប៉ុន្មាន?

វុន ៈ មិនដឹងប៉ុន្មានទេភ្លេចហើយ ។

សេងគា ៈ កាលហ្នឹងមិនលន់ ណុល ឬក្រោយលន់ ណុល?

វុន ៈ កាលលន់ ណុល កប៉ាល់ហោះកំពុងពេញវៃទម្លាក់ហើយ ។

សេងគា ៈ អ៊ូ!៧២-៧៣?

វុន ៈ ប្រហែលប៉ុនហ្នឹងឯង ការកាលហ្នឹងកប៉ាល់ហោះទម្លាក់ ។

សេងគា ៈ ទម្លាក់ហើយការនៅការទៀតអ៊ំ?

វុន ៈ ចា៎!

សេងគា ៈ កាលហ្នឹងគេរៀបការឲ្យ ឬយើងស្រឡាញ់គ្នាគេដណ្តឹង?

វុន ៈ ម៉ែឪរៀបការឲ្យ ហើយស្រឡាញ់ខ្លួនឯងដែល ។

សេងគា ៈ នៅជិតគ្នាអ៊ំ?

វុន ៈ ជិតគ្នា ។

សេងគា ៈ ចាប់ដៃគ្នាអញ្ចឹង កាលហ្នឹងប្តីគាត់ធ្វើអីអ៊ំ?

វុន ៈ កាលរៀបការហើយមិនទាន់ធ្វើអីទេ ។

សេងគា ៈ គាត់ធ្វើស្រែដែរ?

រុន ៖ ធ្វើស្រែដែរ ។

សេងគា ៖ បាទ!ដល់ពេលការហើយបានប៉ុន្មានឆ្នាំបានរត់ចេញម៉ោពីហ្នឹង?

រុន ៖ បានកូនមួយខ្ញុំចេញម៉ោ ។

សេងគា ៖ ការហើយបានមួយឆ្នាំបានកូនមួយ?

រុន ៖ មានមួយឆ្នាំទេ បានពីរឆ្នាំអីនោះទំរាំបានកូន កាលរត់ហ្នឹងក៏គេឲ្យធ្វើទាហាន ធ្វើទ័ពហ្នឹងក៏គាត់រត់ទៅបាត់ទៅ បានប៉ុន្មានឆ្នាំទេបានគាត់ម៉ោវិញ ។

សេងគា ៖ ម៉ោវិញបានកូនមួយ?

រុន ៖ ចា៎! បានកូនមួយហ្នឹងគ្មាននៅផ្ទះទេ រត់តែដើរលេងបាត់ៗពីផ្ទះ ។

សេងគា ៖ ដល់បានកូនមួយអញ្ចឹងទៅ ប្ដីគេហៅយកទៅធ្វើទាហានទៅ?

រុន ៖ អត់ទាន់បានទេ ការហើយអត់ទាន់បានកូនមួយទេ គេហៅយកទៅធ្វើទាហានបាត់ ។

សេងគា ៖ ការហើយមិនទាន់បានកូនមួយផងទៅធ្វើទាហាន?

រុន ៖ ចា៎!

សេងគា ៖ ទៅធ្វើទាហានបានប៉ុន្មានឆ្នាំបានម៉ោវិញ?

រុន ៖ ពីរឆ្នាំហើយ ។

សេងគា ៖ ពីរឆ្នាំម៉ោវិញ៧/៨បានកូនមួយ ដល់បានកូនមួយហើយទៅធ្វើទាហានទៀតឬអត់?

រុន ៖ ដល់បានកូនមួយហើយ ។

សេងគា ៖ អ្នកណាគេម៉ោហៅឲ្យទៅធ្វើទាហានកាលហឹងអុំ?

រុន ៖ មិនដឹងអ្នកណាអ្នកណីទេ ខ្ញុំមិនសូវដឹងដែរ ។

សេងគា ៖ តែអ្នកនៅស្រុកជ្រុំគីរី?

រុន ៖ អ្នកនៅស្រុកនៅភូមិហ្នឹងឯង ។

សេងគា ៖ អត់មានស្គាល់ឈ្មោះទេអុំ?

រុន ៖ អត់ស្គាល់ទេ កាលហ្នឹងកំពុងវឹកវរមិនដឹងអ្នកណាខ្លះយើងមិនដឹង ។

សេងគា ៖ ឲ្យតែឃើញគេម៉ោហៅទៅៗម៉ង?

រុន ៖ ចា៎!

សេងគា ៖ អ្នកណាគេម៉ោមេភូមិ?

រុន ៖ ចេះទៅតាមគ្នាហ្នឹងឯង មើលទំនងនៅក្មេងៗដូចគ្នាចេះតែទៅតាមគ្នាហ្នឹងទៅ ខ្ញុំមិនសូវស្គាល់ដែរ ។

សេង‌គា ៖ កាលហ្នឹងប្តីអ៊ំអាយុប៉ុន្មានហើយ កាលការ?

វុន ៖ មិនដឹងភ្លេច ។

សេងគា ៖ ចុះអ៊ំ?

វុន ៖ ខ្ញុំ១៨-១៩ហើយ ព្រោះវាយូរហើយមានទៅគិតគូរអី ។

សេងគា ៖ ប្តីអ៊ំបងអ៊ំប៉ុន្មានឆ្នាំអ៊ំ?

វុន ៖ ៣ឆ្នាំ ។

សេងគា ៖ អញ្ចឹង២២-២៣អញ្ចឹងអ៊ំ?

វុន ៖ ចាំ!

សេងគា ៖ ដល់ពេលធ្វើទាហានអញ្ចឹងទៅ ដល់ឆ្នាំ៧៥យកអ៊ំទៅដែរ រត់ចេញពីហ្នឹងម៉ោប្តុក៏ម៉េច?

វុន ៖ អត់រត់ទេទៅយកម៉ោ ។

សេងគា ៖ គាត់ទៅយកប្តុម៉េច?

វុន ៖ ចាំ!ឡានគេទៅយក ចេះតែម៉ោតាមឡានគេមិនដឹងណាណី ។

សេងគា ៖ ប៉ុន្តែប្តីអ៊ំជាអ្នកឲ្យទៅយក?

វុន ៖ អ្នកឲ្យទៅយក ។

សេងគា ៖ ចុះប្តីអ៊ំមានទៅទទួលជាមួយទេ?

វុន ៖ អត់ឃើញអត់ដែលឃើញទេ ឡានគេដាក់ម៉ោបានឃើញគេប៉ុនហ្នឹង ។

សេងគា ៖ អូ!អញ្ចឹងប្តីអ៊ំនៅនេះទេ?

វុន ៖ នៅកំពង់ធំ ឡានគេទៅយកពីផ្ទះម៉ោចេះតែទៅៗម្នាក់ៗ កាលម៉ាវីកហ្នឹងគេទៅដឹកម៉ោ អាម្នាក់ៗអាប្រពន្ធទាហានយំឡើងទ្រហឹងមិនដឹងគេដឹកយកទៅវៃចោល មិនដឹងយកទៅធ្វើអីបើយើងអត់ដឹង ។

សេងគា ៖ អញ្ចឹងដឹកគាត់តាមកំពង់ធំវិញអ៊ំ?

វុន ៖ ចាំ!មិនដឹងទៅប្រឡោះណាទៅ ទៅដល់បាភាយណ៍តាំងគោកនោះ ដឹកយកទៅចាក់នោះឯង ។

សេងគា ៖ អូ!ដល់បាភាយណ៍តាំងគោកទៅបានជួបប្តីនៅហ្នឹងវិញ?

វុន ៖ ចាំ!

សេងគា ៖ កាលទៅពីនេះមិនមែនប្តីអ៊ំឲ្យទៅទេ ទៅតាមគ្នាទេ?

វុន ៖ អត់ទេ អត់ឃើញផង ។

សេងគា ៈ ទៅដល់ជួបគ្នានោះ?

វុន ៈ ចាំ!អត់ដឹងពីណាគេយកទៅ ឡានពីណាម៉ោ២ឡានម៉ោដឹកយក ។

សេងគា ៈ ឡានម៉េចទៅ ឡានធំៗឡានទាហាន?

វុន ៈ ឡានទាហាន ។

សេងគា ៈ ដឹកទៅប្រហែលមនុស្សប៉ុន្មាននាក់អីកាលហ្នឹង?

វុន ៈ ២ឡានហ្នឹងមិនដឹងប៉ុន្មាននាក់ ។

សេងគា ៈ ប៉ុន្តែឃើញថាច្រើនអី?

វុន ៈ ឃើញតែច្រើន ។

សេងគា ៈ កាលហ្នឹងឪពុកម្តាយអីអត់ទៅជាមួយទេ?

វុន ៈ អត់ទេ! ។

សេងគា ៈ ទៅតែអី?

វុន ៈ ទៅតែខ្ញុំហើយនឹងកូនមួយតែប៉ុនហ្នឹងឯង ។

សេងគា ៈ ម៉េចបានអីសម្រេចចិត្តទៅ?

វុន ៈ ដឹងយ៉ាងម៉េច បើយើងមិនទៅក៏គេមិនព្រម ។

សេងគា ៈ ចុះបងប្អូនអីផ្សេងទៀតនោះ?

វុន ៈ បងប្អូនខ្ញុំនៅផ្ទះទាំងអស់ គ្មានអ្នកណាចេញទេ ។

សេងគា ៈ គេឲ្យទៅតែអីហ្នឹង ម៉ោពីគេដឹងថាអីមានប្តីជាទាហានឬក៏យ៉ាងម៉េច?

វុន ៈ មានប្តីទាហានហ្នឹង ។

សេងគា ៈ អ្ហូ!ដោយសារអញ្ចឹងបានគេឲ្យទៅតែឯង?

វុន ៈ ចាំ!ទៅតែឯង ។

សេងគា ៈ កាលហ្នឹងអ្នកណាអ្នកឲ្យទៅ មេភូមិ?

វុន ៈ មេភូមិគេ ។

សេងគា ៈ មានចាំឈ្មោះគាត់ទេ ឈ្មោះអីកាលហ្នឹង?

វុន ៈ អត់ចាំផង ស្លាប់បាត់ហើយមើលទៅ នៅផ្ទះមិនដែលឃើញផង ។

សេងគា ៈ ទាល់តែឲ្យនៅជាមួយកូន កូនក៏យកទៅអី?

វុន ៈ កូនក៏យកទៅ ។

សេងគា ៈ បាទ!កាលហ្នឹងឆ្នាំ៧០ប៉ុន្មាន?

វុន ៖ អត់ដឹងទេខ្ញុំ អត់ចាំ ។

សេងគា ៖ កាលហ្នឹងចប់ដាច់លន់ ណុលហើយឬនៅ?

វុន ៖ ដាច់ហើយឬនៅទេខ្ញុំមិនសូវដឹងដែរ ។

សេងគា ៖ ដល់ពេលអ៊ីជិះឡានទៅ ឡើងឡានទៅជាមួយគេហ្នឹងតាមផ្លូវជិះប៉ុន្មានថ្ងៃបានទៅដល់?

វុន ៖ មួយប់មួយថ្ងៃទេកាលហ្នឹង បើមិនម៉ាថ្ងៃក៏មួយប់មួយថ្ងៃដែរទៅដល់ ។

សេងគា ៖ នៅពេលអ៊ីទៅដល់នោះតាមផ្លូវហ្នឹងមានឃើញគេបាញ់គ្នា ឬក៏មនុស្សស្លាប់អីតាមផ្លូវ ទេ?

វុន ៖ អត់បានឃើញផង ។

សេងគា ៖ អត់ឃើញទេ ឡានហ្នឹងគេហ៊ុំជិតអត់?

វុន ៖ អត់ទេគេអត់ហ៊ុំទេ ដាក់តែដំបូល ។

សេងគា ៖ អូ!ដាក់តែដំបូលទេ ប៉ុន្តែចំហរនៅមើលឃើញទេ ប៉ុន្តែអត់មានឃើញអីទេ កាត់តាមភ្នំពេញទេអ៊ី ជិះកាត់តាមភ្នំពេញ?

វុន ៖ អត់ស្គាល់ផងភ្នំពេញទេ ។

សេងគា ៖ អញ្ចឹងកាលហ្នឹងឡានអត់ជិះកាត់តាមហ្នឹងទេ?

វុន ៖ អត់ដឹងជិះកាត់តាមណាខ្ញុំអត់ដែលស្គាល់ផង ។

សេងគា ៖ អូ!អ៊ីអត់ស្គាល់ផង?

វុន ៖ ចាំ!អត់ស្គាល់ទេតាំងពីដើមម៉ោ ទឹមស្គាល់ឥឡូវនេះទេ ។

សេងគា ៖ ដល់ពេលទៅដល់ដឹងតែគេហៅស្រុកបារាយណ៍នេះទៅ?

វុន ៖ គេហៅស្រុកបារាយណ៍ចេះតែស្រុកបារាយណ៍គេទៅ មិនដែលស្គាល់ផង ស្រុកខ្ញុំជនបទសុទ្ធ ព្រៃសុទ្ធម៉ងអត់មានទីក្រុង សូម្បីតែវីដេអូក៏គ្មានដែរមិនដែលមានមិនដែលឃើញទេមានតែរ៉ាត់យ៉ូមួយៗនោះឯងស្តាប់តាមរ៉ាត់យ៉ូតិចតួចតែប៉ុណ្ណឹងឯង បើក្រនៅតែព្រៃភ្នំរកស៊ីតាមតែព្រៃភ្នំ សុទ្ធតែព្រៃភ្នំ ។

សេងគា ៖ ហើយពេលដែលឡើងឡានទៅហ្នឹង គេមានប្រាប់ថាទៅធ្វើអីៗទេ?

វុន ៖ អត់ដឹងទេ ដឹងតែថាអ្នកប្រពន្ធជាទាហានគេឲ្យទៅ យើងថាមិនទៅ គេថាមិនព្រម ។

សេងគា ៖ មិនព្រមហ្នឹងគេចង់ធ្វើម៉េចអ៊ី?

វុន ៖ មិនដឹងគេធ្វើម៉េចទេ ដឹងតែថាមិនទៅមិនបានដឹងតែឲ្យទៅ ។

សេងគា ៖ អ្នកណាអ្នកឲ្យទៅអាពត?

វុន ៖ មិនដឹង ។

សេង៉គា ៖ គេត្រូវតែឲ្យទៅអញ្ចឹង?

វុន ៖ ចា៎!

សេង៉គា ៖ ហើយក៏យកកូនទៅៗ?

វុន ៖ ចា៎!

សេង៉គា ៖ កាលហ្នឹងកូនបានប៉ុន្មានឆ្នាំហើយ២?

វុន ៖ កូនខ្ញុំទើមបានប៉ុន្មានខែហ្នឹង ៤-៥ខែហ្នឹង ។

សេង៉គា ៖ ៤-៥ខែគេឲ្យទៅក៏ជិះឡានទៅៗ?

វុន ៖ ចា៎!ប៉ុនស្លាប់ហើយកូនខ្ញុំអាបង២អស់២ អានេះ៤នាក់នេះក្រោយទេ ។

សេង៉គា ៖ អ្ហ៎!អញ្ចឹងទាំងអស់៦នាក់អ៊ី?

វុន ៖ ចា៎!

សេង៉គា ៖ បង២នាក់ហ្នឹងឈ្មោះអីខ្លះអ៊ី?

វុន ៖ ឈ្មោះវិតមួយ ហើយមីស្រីនោះខ្ញុំកើតនៅក្នុងព្រៃអត់បានដាក់ឈ្មោះឲ្យទេស្រី រត់រឡាក់រឡើកៗទៅក៏ខ្ញុំទាស់ឈើទៅដាច់ទឹកដោះស្លាប់មួយស្រី ។

សេង៉គា ៖ អញ្ចឹងកូនប្រុសមួយកូនស្រីមួយ?

វុន ៖ ចា៎!

សេង៉គា ៖ ទាស់ទឹកដោះអ៊ី?

វុន ៖ ទាស់ពេលដែលយើងរត់ហ្នឹង ដល់ពេលយើងសសៃខ្ចីរត់កាត់ព្រៃភ្នំអញ្ចឹងទៅ ខ្លះស្លាប់អាមួយនោះស្លាប់នឹងឡានកិន ឡានកៀរយ៉ាងម៉េច ។

សេង៉គា ៖ អញ្ចឹងកូន២ដែលស្លាប់ហ្នឹងគឺស្លាប់កាលសម័យហ្នឹងទាំង២អ៊ី?

វុន ៖ ចា៎!

សេង៉គា ៖ កូនប្រុសស្លាប់ដោយសារអី?

វុន ៖ ឡានកៀរម៉េច ។

សេង៉គា ៖ ឡានកិនកាលហ្នឹងមានឡានដែរ?

វុន ៖ មាន ឡាននៅក្នុងព្រៃ ។

សេង៉គា ៖ ៤នាក់ហ្នឹងបានកើតក្រោយ ដល់ពេលរត់ទៅជួបប្ដីនៅស្រុកបារាយណ៍ហ្នឹងទៅដល់ភ្លាមជួបភ្លាមឬទៅដល់ ឬទៅដល់បានប៉ុន្មានថ្ងៃបានជួប?

វុន ៖ ទៅដល់ជួប ។

សេង៉គា ៖ ហើយអ្នកទៅដឹកហ្នឹងសុទ្ធតែទាហាន?

វុន ៖ សុទ្ធតែទាហាន ។

សេង៉គា ៖ គ្នាប៉ុន្មានទៅទាហានម៉ោដឹកហ្នឹង?

វុន ៖ មិនដឹងប៉ុន្មាននាក់ទេ ។

សេង៉គា ៖ ជួបប្តីកាលហ្នឹងប្តីម៉ោទទួលស្គាល់ទេអី?

វុន ៖ គាត់អីស្គាល់បែកគ្នាបានប៉ុន្មានឆ្នាំហ្នឹង ។

សេង៉គា ៖ ហើយពេលទៅដល់ភូមគេឲ្យធ្វើអីនៅស្រុកបារាយណ៍នោះ?

វុន ៖ គ្មានធ្វើអីដកស្ទូងហ្នឹងឯង ។

សេង៉គា ៖ អត់មានលើកកាប់ខណ្ឌប្រឡាយអីទេ?

វុន ៖ អត់ ។

សេង៉គា ៖ ទៅឲ្យធ្វើស្រែចំការនៅហ្នឹងវិញ?

វុន ៖ ចា៎!

សេង៉គា ៖ មិនមាននៅបន្ទាយជាមួយប្តីទេ?

វុន ៖ អត់ ។

សេង៉គា ៖ ប៉ុន្តែប្តីនៅធ្វើទាហានហ្នឹងដដែល?

វុន ៖ មិនដឹងដែរ មិនដឹងគេធ្វើទាហានឬធ្វើអីខ្ញុំមិនដឹងដែរទៅដល់ហ្នឹងខ្ញុំវាលែងដឹងហើយ ។

សេង៉គា ៖ អីមានឃើញគាត់កាន់កាំភ្លើងដែរ?

វុន ៖ អត់ ។

សេង៉គា ៖ អត់កាន់ទេ?

វុន ៖ មិនដែលឃើញកាន់ផង កាន់កាំភ្លើងកាលនៅធ្វើទ័ពប៉ុនកាន់ ។

សេង៉គា ៖ បាទ! ទៅដល់ស្រុកបារាយណ៍អត់ឃើញកាន់ទេ?

វុន ៖ នៅដល់ស្រុកហ្នឹងមិនដែលឃើញកាន់អីផង ។

សេង៉គា ៖ ហើយគេឲ្យនៅជាមួយគ្នាឬបែកគ្នាកាលហ្នឹង?

វុន ៖ នៅជាមួយគ្នា ។

សេង៉គា ៖ នៅជាមួយគ្នា គេអត់បំបែកគ្នាទេ?

វុន ៖ របំបែកគ្នាតែពីផ្ទះទៅហ្នឹង ។

សេង៉គា ៖ អ៊ូ! ទៅដល់នោះជុំគ្នារហូត?

រុន ៖ ចា៎!

សេងគា ៖ ហើយទៅនៅបាកាយណ៍បានប៉ុន្មានឆ្នាំអ៊ំ?

រុន ៖ ខ្ញុំអត់ចេះចាំទេ ។

សេងគា ៖ តាំងពីអ៊ំទៅហ្នឹងយូរប៉ុណ្ណាទៅបានម៉ោនេះចប់ខ្មែរក្រហម ហើយទឹមម៉ោ អ្ហ៊ូ!ឬដល់ចប់៧៩ហើយបានម៉ោហ្នឹងឬក៏ម៉ោ ហ្នឹងរហូត អ៊ំម៉ោនេះនៅឆ្នាំណាអ៊ំ?

រុន ៖ អត់ដឹងឆ្នាំណាទេ ម៉ោយូរហើយ ។

សេងគា ៖ អញ្ចឹងម៉ោយូរហើយអ៊ំ ដំណាលគ្នាជាមួយពូប្រធានភូមិទេ?

រុន ៖ ម៉ោជាមួយគ្នាហ្នឹងឯង គេដឹកម៉ោជាមួយគ្នាហ្នឹងឯង ។

សេងគា ៖ អ្ហ៊ូ!ម៉ោជាមួយពូប្រធានភូមិហ្នឹង អ្ហ៊ូ!ជំនាន់៩១មកម្លោះម៉ោដែរ?

រុន ៖ ចា៎!

សេងគា ៖ ចុះអ៊ំម៉ោតាមអន្លង់វែងម៉ោតាមគាត់រហូត?

រុន ៖ ចា៎!ម៉ោជាមួយគ្នាហ្នឹងឯង ជាមួយគ្នាទាំងអស់មា៉ភូមិចង់មា៉ភូមិហ្នឹង មា៉ភូមិហ្នឹងឯង ។

សេងគា ៖ អ្ហ៊ូ!មា៉ភូមិហ្នឹងម៉ោជាមួយគ្នាទាំងអស់?

រុន ៖ ចា៎!

សេងគា ៖ អញ្ចឹងគាត់ធ្វើមេភូមិហ្នឹងយូរហើយ?

រុន ៖ គាត់ធ្វើយូរដែលហើយ ។

សេងគា ៖ ទាល់ពេលអ៊ំនៅស្រុកបាកាយណ៍ហ្នឹងនៅរហូត គាត់ហ្នឹងគាត់ទាហានដែរពូគាត់ទាហាន ដែរពូប្រធានភូមិ?

រុន ៖ អត់ទេ!អត់ជួបគ្នាទេ រត់បាត់ ។

សេងគា ៖ រត់ម៉ោអន្លង់វែង?

រុន ៖ ចា៎!

សេងគា ៖ អ៊ំម៉ោអន្លង់វែងបានជួបគ្នា?

រុន ៖ ចា៎!ជួបគ្នាដូចបងដូចប្អូនអញ្ចឹងទៅ ។

សេងគា ៖ មានជួបពីនោះម៉ោទេ?

រុន ៖ ចេះតែនៅជាមួយគ្នាអញ្ចឹងទៅ មានការអីក៏រត់ទាំងអស់គ្នាអញ្ចឹងទៅ ។

សេងគា ៖ ហើយអ៊ំនៅហ្នឹងអ៊ំហូបចុកអីយ៉ាងម៉េចដែរ?

រុន ៖ បានអីហូបនៅនោះ មានតែតាឡូង ហូបតែត្រកួន ហូបតែចេកហ្នឹង ។

សេងគា ៖ អញ្ចឹងនៅបារាយណ៍គេឲ្យហូបអីអ៊ំ?

វុន ៖ នៅបារាយណ៍ហូបបបរ ។

សេងគា ៖ ហូបបបរហូបអី?

វុន ៖ ចា៎!តាំងចេញពីស្រុកម៉ោហូបបបររហូត ។

សេងគា ៖ ហើយគេឲ្យធ្វើការយ៉ាងម៉េចដែរអ៊ំកាលហ្នឹង?

វុន ៖ តាមម៉ោងគេឲ្យឈប់ម៉ោង១១អីអញ្ចឹងទៅ ម៉ោង១ចុះទៅធ្វើការទៀតទៅ ម៉ោង៥ អញ្ចឹងងើប ម៉ោង៥-៨ឡើងទៅ ។

សេងគា ៖ អ៊ំនៅស្រុកបារាយណ៍បានកូនមួយទៀតកូនស្រីហ្នឹង?

វុន ៖ ចា៎!

សេងគា ៖ យកប្ដីទៅក៏បានកូនមួយទៀត ហើយកើតបានប៉ុន្មានខែក៏ស្លាប់ហ្នឹង?

វុន ៖ ស្លាប់នៅក្នុងព្រៃនោះបាន៨ខែ ។

សេងគា ៖ ស្លាប់នៅបារាយណ៍ដែរឬនៅអន្លង់វែង?

វុន ៖ ស្លាប់នៅណាទេ ភ្លេចហើយនឹកមិនឃើញទេ ។

សេងគា ៖ អញ្ចឹង!ចេញពីស្រុកបារាយណ៍ហើយទៅណា?

វុន ៖ ចេញពីបារាយណ៍ម៉ោចូលព្រៃហ្នឹងរហូត ។

សេងគា ៖ អញ្ចឹងទៅខាងអន្លង់វែងវិញ?

វុន ៖ មិនដឹងខាងណាបើខ្ញុំមិនសូវស្គាល់ ដឹងតែព្រៃហ្នឹងឯង ។

សេងគា ៖ អញ្ចឹងតែអត់មានគេធ្វើបាបអី វៃដំអីទេអ៊ំ?

វុន ៖ អាអ្នកណាដែលវាត្រូវនេះហ្នឹងសម្លាប់ចោលហែងបណ្ដោយរកមុខមិនឃើញ ។

សេងគា ៖ អ្នកណាត្រូវម៉េចអ៊ំ?

វុន ៖ ដូចថាគេត្រូវសម្លាប់អញ្ចឹងគេចាប់ទៅបាត់តែម្ដងទៅ អត់ដឹង ។

សេងគា ៖ អ្ហូ!ចាប់ទៅបាត់ទៅអ៊ំ?

វុន ៖ ចា៎!ចាប់ទៅបាត់ទៅអត់ដឹងទេ គេចាប់ទៅវៃអត់ឲ្យឃើញទេ ។

សេងគា ៖ អ៊ំមានចាំថានៅបារាយណ៍រយៈពេលប៉ុន្មានទេអ៊ំ ប្រហែលជាប៉ុន្មានដែរអ៊ំតាមអ៊ំស្មាន មើល?

វុន ៖ មិនចេះស្មានទេ ។

សេងគា ៖ នៅយូរដែរឬក៏ម៉េច?

រុន ៖ នៅយូរដែរបើ២ឆ្នាំក៏៣ឆ្នាំ ។

សេងគា ៖ អ្ហូ!ប្រហែលជា៣ឆ្នាំដែរអ៊ី?

រុន ៖ ចា៎!ខ្ញុំវាអត់ចេះគិត និយាយរួមទៅខ្ញុំវាអត់ចេះគិត ។

សេងគា ៖ ៣ឆ្នាំបានបែកទៅអន្លង់វែង ហើយបានរត់ចូលព្រៃអ៊ី?

រុន ៖ រត់ចេញរហូត ។

សេងគា ៖ ម៉េចបានរត់ចេញពីនោះ?

រុន ៖ មិនដឹងយ៉ាងម៉េចថាចេះថាចុះ ផ្អើលតាមគ្នារហូតរជីករដែលអញ្ចឹងទៅ ។

សេងគា ៖ អញ្ចឹងអត់មានអ្នកណាគេអ៊ីអត់មានស្គាល់ឈ្មោះអ្នកណាគេអ្នកឲ្យរត់ម៉ោ?

រុន ៖ អត់ដឹងផង ។

សេងគា ៖ អញ្ចឹងទាល់តែរត់ដល់អន្លង់វែងបានជួបលោកមេភូមិសៀនទៅគាត់?

រុន ៖ ជួបគ្នារដាក់រដុបទៅ កាលរត់ចេញពីភូមិម៉ោមិនដឹងណាណី គេថារត់ៗតែម្តងរត់ដាច់ខ្យល់ងាប់ហើយ ។

សេងគា ៖ ចេះតែរត់ទៅអ៊ី?

រុន ៖ ចេះតែរត់ទៅ ។

សេងគា ៖ កាលហ្នឹងមានដឹងថាខ្មាចអីបានរត់ទេ ខ្មាចយួនឬខ្មាចអី?

រុន ៖ មិនដឹងជាខ្មាចស្អី បើអត់ដឹង ។

សេងគា ៖ ចេះតែរត់តាមគ្នាទៅអ៊ី?

រុន ៖ ចេះតែរត់តាមគ្នាទៅឲ្យតែស្គាល់ផ្លូវដើរៗចេះតែទៅៗ ។

សេងគា ៖ ចុះពេលកូនស្លាប់អីមានបានកប់ត្រឹមត្រូវដែលអ៊ី?

រុន ៖ គ្មានបានកប់ទេ គ្រាន់តែ បើកូនខ្ញុំអាបងនោះបានទុកដាក់ ។

សេងគា ៖ បាទ!ចុះកូនពៅ?

រុន ៖ បន្ទាប់បងហ្នឹងអត់ទេ កាយកប់ចោលនៅក្នុងព្រៃ អាបងនោះខ្ញុំកប់បានត្រឹមត្រូវ ដល់ពេលរៀបឡានជីកម៉ោនេះទៅ បានកាយលាយយកធាតុយកអីម៉ោទុកដាក់នេះ ។

សេងគា ៖ អញ្ចឹងកប់នៅណាអ៊ី?

រុន ៖ កូនខ្ញុំមីស្រីហ្នឹង?

សេងគា ៖ បាទ!

រុន ៖ មីស្រីហ្នឹងមិនដឹងណាទេ មីស្រីអត់ដឹង បើប្រុសនោះអាបងបង្អស់ហ្នឹងនៅជងទង់ស្លាប់ ។

សេងគា ៖ ដងទង់នៅកំពត់?

វុន ៖ ដងទង់ក្នុងព្រៃនោះ មិនដឹងគេហៅ ។

សេងគា ៖ ស្តៅយើងនេះទេ បាត់ដំបងនេះ?

វុន ៖ នៅជាប់ដីថៃហ្នឹង ។

សេងគា ៖ កប់ត្រង់ហ្នឹងហើយទៅរកកន្លែងកប់ឃើញដែលអឺ?

វុន ៖ ឃើញខ្ញុំវត់ម៉ោខ្ញុំគាស់កូនខ្ញុំលាយយកឆ្អឹងម៉ោតាម ហើយដឹកឡានម៉ោ កាលហ្នឹងកូនខ្ញុំអាចងហ្នឹងវាធំហើយអាយុ១៥ឆ្នាំហើយ ។

សេងគា ៖ ហើយនៅក្នុងកំឡុងពេលហ្នឹងអ៊ុំជួបហេតុការណ៍អ្វីខ្លះទៅអ៊ុំ?

វុន ៖ ឥឡូវនេះ?

សេងគា ៖ អត់ទេ!កាលសម័យនោះ កាលសម័យពីលន់ ណុល រហូតដល់សម័យខ្មែរក្រហមអីអញ្ចឹងទៅ?

វុន ៖ អត់ចេះនិយាយទេ ។

សេងគា ៖ មានត្រូវគ្រាប់ត្រូវអីទេ?

វុន ៖ ខ្ញុំអត់ដែលត្រូវទេ ។

សេងគា ៖ អត់ដែលអីទេ សុខសាន្តរហូតអ៊ុំ?

វុន ៖ សុខសាន្តរហូត ប៉ុនៗតែវាភ័យៗហ្នឹងឯង ចេះតែរត់លូនមុខលូនក្រោយ ដេញមុខដេញក្រោយអញ្ចឹងទៅចេះតែទៅ ដួនកាលកាត់គ្រាប់ ។

សេងគា ៖ ហើយមានជួបមេដឹកនាំធំៗអីដូចតាម៉ុកអី មានជួបទេមានធ្លាប់ឃើញគាត់ទេ?

វុន ៖ អត់ដែលឃើញគាត់ផង ប៉ុន្តែឮតែឈ្មោះប៉ុនខ្ញុំអត់ស្គាល់ៗគាត់ទេ ។

សេងគា ៖ ហើយអ្នកផ្សេងទៀត ដូចជាសុខ គង់អីអ៊ុំធ្លាប់ឃើញគាត់ទេ?

វុន ៖ ឃើញតែខ្ញុំអត់ស្គាល់ ។

សេងគា ៖ អ៊ូ!អត់ស្គាល់គាត់ទេ?

វុន ៖ អត់ស្គាល់គាត់ ខ្ញុំមិនសូវចេះស្គាល់ទេ ប្រហែលម៉ោជាមួយគ្នាមិនដឹងខ្ញុំមិនសូវចេះស្គាល់ទេ អ្នកខាងនេះម៉ោមុនខ្ញុំគាត់អ្នកម៉ោមុនខ្ញុំ ។

សេងគា ៖ បាទ!អ៊ុំអត់មានស្គាល់ពីណាគេក្រៅពីមេភូមិខ្លះទេ ចុះស្គាល់តាអានទេ?

វុន ៖ តាអាននៅ តួគីហ្នឹង?

សេងគា ៖ បាទ!អាចារ្យហ្នឹង?

រុន ៖ ជាមួយគាត់ហ្នឹងរហូត ។

សេងគា ៖ នៅជាមួយគាត់ហ្នឹងរហូតដែរ?

រុន ៖ ចា៎!នៅជាមួយគាត់ហ្នឹង ។

សេងគា ៖ គាត់អ្នកដឹកនាំម៉ោ?

រុន ៖ មិនដឹងម៉េចទេនែ៎ បើឃើញរត់តាមគ្នាតែរហូតអញ្ចឹង ។

សេងគា ៖ អញ្ចឹងក៏ម៉ោជាមួយគាត់រហូតទៅ?

រុន ៖ ម៉ោជាមួយគ្នារហូត ។

សេងគា ៖ ម៉ោពីអន្លង់វែងម៉ោអញ្ចឹង?

រុន ៖ ចា៎!ម៉ោជាមួយតា សឿន ហ្នឹងរហូត ស្គាល់តែតាសឿន ហើយតាដុស ហ្នឹងឯង ច្បាស់គាត់អ្នកយកម៉ោ ។

សេងគា ៖ តាសឿន នឹងតាដុស?

រុន ៖ តាដុសហ្នឹងឯង តាដុស តាអានហ្នឹង ។

សេងគា ៖ គាត់ចាស់ៗប៉ុន្មាននាក់ហ្នឹង?

រុន ៖ ម៉ោជាប់រហូតជាមួយគាត់ហ្នឹង គាត់យកម៉ោរហូតដឹកទៅណាក៏គាត់ជាអ្នកដឹកម៉ោ ដឹកទៅណាក៏គាត់អ្នកដឹកម៉ោ ផ្លាស់ទៅណាក៏គាត់ជាអ្នកដឹក ។

សេងគា ៖ ហើយដល់រយៈពេល៨០ជាងបានអ៊ីមានកូនម៉ោនៅនេះ ៨០ជាងកូនកើតនៅនោះទេ នៅអន្លង់វែងអ៊ី?

រុន ៖ កូនកើតនៅនោះ អន្លង់វែងនោះទាំងអស់ហ្នឹង ។

សេងគា ៖ អ្ហ៎!កើតទាំង៤នាក់អ៊ី?

រុន ៖ ចា៎!កូនកើតនៅនោះទាំងអស់ កើតនៅក្នុងព្រៃទាំងអស់ ប៉ុនកាលហ្នឹងយើងលែងសូវរត់ហើយដូចជាដឹកដាក់ត្រង់ណានៅត្រង់ហ្នឹងធ្វើផ្ទះនៅត្រង់ហ្នឹង ដាំដំណាំហូបត្រង់ហ្នឹង ២ឆ្នាំ-៣ឆ្នាំបានផ្លាស់ទៅទៀតទៅ ។

សេងគា ៖ ដូររហូតអ៊ី?

រុន ៖ ចា៎!ដូររហូត ។

សេងគា ៖ ចេះតែរត់ទៅៗមកដល់នេះ កាលហ្នឹងចេះឡានម៉ោឬក៏ស្អី?

រុន ៖ ជិះឡានរហូត ម៉ាកន្លែងមួយទៅកន្លែងមួយជិះឡានរហូត អត់ដែលដើរទេ ។

សេងគា ៖ ប៉ុន្តែគ្នាម៉ោជាមួយមានគ្នាច្រើនទេអ៊ី?

រុន :		ច្រើនទាំងអស់ហ្នឹង ។

សេងគា :	ប្រហែលជាប៉ុន្មាននាក់ទៅកាលហ្នឹង?

រុន :		កាលហ្នឹងប៉ុន្មានភូមិហ្នឹងម៉ោជាប់គ្នារហូត ។

សេងគា :	តែអ៊ំអត់បានចាំអ្នកណាគេខ្លះទេ តែប្តីមកដល់នេះគាត់ធ្វើទាហានវិញទៀត?

រុន :		គេឲ្យធ្វើ ។

សេងគា :	គេឲ្យធ្វើអ៊ំ អត់ដឹងថាគាត់គេឲ្យកាន់ខាងអីទេអ៊ំម៉ោនេះ?

រុន :		មិនគ្មានកាន់ខាងអីផង គេមិនដែលឲ្យទៅហាត់ទៅណាទេ ។

សេងគា :	សម័យហ្នឹងរហូតសុខសាន្តរហូតអ៊ំអត់មានអីទេ?

រុន :		ចា៎!អត់មានអី ។

សេងគា :	ហើយមកដល់នេះបានដីធ្វើចំការច្រើនទេអ៊ំ?

រុន :		ដីបានបន្តិចដែលហ្នឹង គេចែកឲ្យខ្លះអញ្ចឹង ចាប់បានខ្លះទៅ ចេះតែរុកៗព្រៃកាប់បានអីខ្លះទៅ ។

សេងគា :	ចុះអ៊ំខ្ញុំចង់សួរអ៊ំទាក់ទងបន្តិចទៀតដែល អ៊ំយល់ឃើញយ៉ាងម៉េចដែរដូចថាពីមុនម៉ោមិនធ្លាប់មានការកាត់ទោស តែឥឡូវហ្នឹងមានគេកាត់ទោសមេដឹកនាំកំពូលៗដែលដឹកនាំប្រទេសឲ្យទៅអញ្ចឹង គេកាត់ទោសអញ្ចឹងអ៊ំយល់យ៉ាងម៉េចដែរ?

រុន :		អត់យល់អីទេ បើខុសតាមច្បាប់អញ្ចឹងទៅ ។

សេងគា :	អញ្ចឹងអ៊ំយល់ថាបើខុសធ្វើតាមច្បាប់អញ្ចឹងទៅអ៊ំ?

រុន :		ចា៎!អាហ្នឹងវាអញ្ចឹង ។

សេងគា :	អ៊ំអត់តូចចិត្តអត់ខឹងសម្បារអីទេ?

រុន :		អត់ទេ!អានេះតាមច្បាប់យើងរស់នៅក្រោមច្បាប់ តែច្បាប់ដឹកនាំម៉េចអញ្ចឹងហើយ ។

សេងគា :	បាទ!ព្រោះអីកុំម៉ោពីមេដឹកនាំទាំងអស់ហ្នឹងក៏ប្រទេសមិនអញ្ចឹងដែរ អញ្ចឹងអ៊ំអត់យល់ថាម៉េចទេ?

រុន :		អត់ ។

សេងគា :	ហើយរាល់ថ្ងៃអ៊ំមានដែលយករឿងរ៉ាវហ្នឹងប្រាប់កូនចៅពីមុនម៉ោទេ ដែលនិយាយប្រាប់ទេ ?

រុន :		ប្រាប់វាខ្លះៗដែល ។

សេងគា :	ហើយកូនគិតថាយ៉ាងម៉េចដែរ?

វុន ៈ កូនខ្ញុំអត់ថាអីដែរ បើច្បាប់យើងរស់នៅក្រោមច្បាប់ទាល់តែគោរពច្បាប់ ។

សេងគា ៈ ពីរឿងអ៊ីមានរឿងឈឺចាប់ពីសម័យខ្មែរក្រហម ដូចមានបង២នាក់ស្លាប់អីអញ្ចឹង អ៊ីមានប្រាប់កូន មាននិយាយប្រាប់កូនពីដំណើររឿងពីមុនម៉ោទេ?

វុន ៈ ប្រាប់ ។

សេងគា ៈ ហើយកូនជឿទេអ៊ី?

វុន ៈ កូនវាជឿខ្លះ អត់ខ្លះ ។

សេងគា ៈ ជឿខ្លះ អត់ខ្លះអ៊ី?

វុន ៈ ចា៎!កូនវាចេះអក្សរចេះរៀនសូត្រ អត់តែខ្ញុំ ខ្ញុំល្ងង់តែខ្ញុំ ។

សេងគា ៈ បាទ!បើអ៊ីអត់ចេះអក្សរអញ្ចឹងអ៊ីឲ្យកូនទៅរៀនឲ្យចេះទាំងអស់គ្នា?

វុន ៈ វាចេះតិចតួចវាមិនបានចេះជ្រៅជ្រះទេ គ្រាន់មើលចេះតិចតួចៗរកស៊ី ។

សេងគា ៈ កាលដែលរត់ចេះរត់ចុះ មានជួបមេធំគេប្រជុំគេអីទេកាលហ្នឹង?

វុន ៈ ប្រជុំខ្ញុំមិនដែលបានទៅទេ ។

សេងគា ៈ អ៊ីអត់ស្គាល់គេទៀត?

វុន ៈ ចា៎!

សេងគា ៈ អត់ចាំឬក៏អត់ស្គាល់អ៊ី?

វុន ៈ អត់ស្គាល់ផង អត់សូវចាំផង ចុះបើយើងរត់អញ្ចឹងអ្នកណាហានទៅចោលកូននោះ ។

សេងគា ៈ អញ្ចឹងគេទៅប្រជុំអ៊ីនៅតែផ្ទះអ៊ី?

វុន ៈ ចា៎!

សេងគា ៈ ប៉ុន្តែរត់ព្រៃបានបាយបានអីហូបដែរអ៊ី?

វុន ៈ មានខ្លះអត់ខ្លះអញ្ចឹងទៅ ។

សេងគា ៈ ប៉ុន្តែមិនសូវអត់ទេ?

វុន ៈ ចា៎!

សេងគា ៈ បាទ!អត់អីទេចុះក្រោយអ៊ីមានពាក្យអីអ៊ីចង់បន្ថែមទៀតទេ ខ្ញុំអស់ពាក្យអីសួរអ៊ីទៀតហើយ?

វុន ៈ ទេខ្ញុំមិនចេះនិយាយទេ ។

សេងគា ៈ បាទ!ដូចខ្ញុំនិយាយអញ្ចឹងរឿងរ៉ាវដែលខ្ញុំសួរអ៊ំអញ្ចឹង បាទខ្ញុំយកបទសម្ភាសន៍ទៅសរសេរចងក្រងជាឯកសារ បាទ!អ៊ំនិយាយជាមួយខ្ញុំអញ្ចឹងអ៊ំមានអារម្មណ៍យ៉ាងម៉េចដែរភ័យទេអ៊ំ?

វុន ៈ អត់មានភ័យអីទេ ប៉ុន្តែគ្រាន់តែវាល្ងង់មិនចេះនិយាយ ។

សេងគា ៈ អ្ហូ!តែខ្ញុំសូមយកពាក្យដែលអ៊ំនិយាយហ្នឹងយកទុកជាឯកសារខ្ញុំអត់អីទេអ៊ំ?

វុន ៈ មានអីទេ ។

សេងគា ៈ បាទ!ខ្លាចអ៊ំភ័យ ខ្លាចអ៊ំអីអញ្ចឹងសួរហើយ ព្រោះតាមច្បាប់ បើយើងយកអីទៅប្រើប្រាស់ធ្វើអីមួយទាល់តែយើងសុំគេសិន បាទ!បើអ៊ំថាអត់អី អត់អីហើយ ប៉ុន្តែអត់អីទេមិនមែនដឹកនាំនយោបាយទេ តែយើងយកប្រវត្តិមុនៗអញ្ចឹងយើងមានបទពិសោធខុសៗគ្នាអញ្ចឹងអ៊ំ ប៉ុន្តែអ៊ំមានបទពិសោធច្រើនប៉ុន្តែអ៊ំអត់ចេះចាំ អ៊ំអត់ចេះនិយាយហើយខ្ញុំសួរទៅអ៊ំអត់ចាំ បើអ៊ំចាំរឿងអ៊ំរឿងអ៊ំវែងឆ្ងាយណាស់អ៊ំ?

វុន ៈ វែង តែខ្ញុំវាមិនចេះមិនដឹងនិយាយថាម៉េច ។

សេងគា ៈ ហើយអ៊ំអត់ចាំកន្លែងអីសោះ ចុះអ៊ំកាលកើតកូននៅតាមព្រៃមានឆ្មបមានអីទេអ៊ំ?

វុន ៈ មាន ។

សេងគា ៈ មានឆ្មបដែរ?

វុន ៈ ឆ្មបរត់ជាមួយគ្នាអីអញ្ចឹងទៅ ។

សេងគា ៈ ឆ្មបនោះឈ្មោះអីគេអ៊ំ?

វុន ៈ អ្ហូ!អត់ស្គាល់ទេ ប៉ុន្តែគេមកជួយកើតជួយអញ្ចឹងទៅ អ្នកណាមានអាសន្នអីជួយគ្នាអញ្ចឹងទៅ ។

សេងគា ៈ អ្ហូ!ជួយគ្នាទាំងអស់អ៊ំ?

វុន ៈ ជួយគ្នាទាំងអស់ ស្រោគ្នាណាស់នៅក្នុងព្រៃជួយគ្នាណាស់ ។

សេងគា ៈ បាទ!ដូចពាក្យខ្មែរគេថា“នៅផ្ទះម្តាយទីទៃ នៅព្រៃម្តាយតែមួយ”អ៊ំ?

វុន ៈ ចា៎!ជួយគ្នាគគ្រឹកគគ្រេងណាស់ ដល់ឥឡូវនេះគេខំរកស៊ីរៀងៗខ្លួន ។

សេងគា ៈ ប៉ុន្តែឥឡូវដល់ពេលមានបុណ្យទានអីបងប្អូនមកជួយគ្នាទេនៅនេះ?

វុន ៈ ជួយគ្នា ។

សេងគា ៈ បាទ!អញ្ចឹងអរគុណអ៊ំច្រើនអ៊ំ ដែលបានចំណាយពេលឲ្យខ្ញុំសម្ភាសន៍អញ្ចឹង អញ្ចឹងជំរាបលាអ៊ំ ។

វុន :  ចា៎!

សេផគា :  បាទ!អរគុណ ៗ

**ចប់**